ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy.

N° ១១២ រ៤ម.សឧក.ចក.

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៤

# ប្រកាស
## ស្តីអំពី
## សញ្ញាសំគាល់ស្តង់ដារឧស្សាហកម្មកម្ពុជា

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និងសេវា

-បានឃើញ អនុក្រឹត្យ លេខ៤២ អនក្រ.បក ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពី ស្តង់ដារឧស្សាហកម្មកម្ពុជា

-យោងកំណត់ហេតុអង្គប្រជុំគណៈកម្មការបច្ចេកទេសស្តង់ដារឧស្សាហកម្ម លើកទី១០ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពី ការប្រជុំ ពិនិត្យនិងពិភាក្សាលើការរៀបចំស្តង់ដារឧស្សាហកម្មកម្ពុជាអំពីផលិតផលអគ្គិសនី និងអេឡិចត្រូនិច ដោយយកលំនាំតាមទាំងស្រុងតាមស្តង់ដារអន្តរជាតិ IEC (International Electrotechnical Commission) និងសញ្ញា សំគាល់ស្តង់ដារឧស្សាហកម្មកម្ពុជា

-យោងតាមតំរូវការនៃផ្នែកស្តង់ដារូបនីយកម្មឧស្សាហកម្ម ។

## <u>សំរេច</u>

<u>ប្រការ ១</u> : បង្កើតសញ្ញាសំគាល់ស្តង់ដារឧស្សាហកម្មកម្ពុជា សំរាប់សំគាល់ការអនុលោមតាមស្តង់ដារឧស្សាហកម្មកម្ពុជា ដែលមានប្រភេទដូចខាងក្រោម :

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ ទូរសារ : (៨៥៥) ២៣-៤២៨ ២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh ( Cambodia ) Tel / Fax : (855)23-428 263

១-សញ្ញាស្តង់ដារផលិតផលសំរាប់បិទភ្ជាប់ ឬបោះពុម្ពនៅលើស្លាកផលិតផល ដែលបានអនុលោមតាមស្តង់ដារឧស្សាហកម្មកម្ពុជា មានលំនាំតាមអក្សរឡាតាំង "ISC" និងមានលេខសំគាល់នៅពីក្រោម ។

**CS 00x-00y**

<u>រូបសញ្ញាស្តង់ដារផលិតផល</u>

សញ្ញាស្តង់ដារផលិតផលមិនត្រូវបានកំណត់អំពីពណ៌ឡើយ ប៉ុន្តែទំហំអាចតូច ឬធំបានដោយត្រូវសមាមាត្រទៅនឹងគំរូដែលមានភ្ជាប់ជាមួយនៅក្នុងឧបសម្ព័ន្ធ " ក " ។

២-សញ្ញាសុវត្ថិភាពសំរាប់បិទភ្ជាប់ ឬបោះពុម្ពនៅលើស្លាកផលិតផលដែលបានអនុលោមតាមស្តង់ដារសុវត្ថិភាព មានលំនាំតាមអក្សរឡាតាំង " S " និងមានសរសេរ អក្សរខ្មែរ " **សុវត្ថិភាព** " (ដោយប្រើ Font Limon R1) នៅចំកណ្តាលអក្សរឡាតាំង " S " និងមានលេខសំគាល់នៅពីក្រោម ។

**CS 00x-00y**

<u>រូបសញ្ញាស្តង់ដារសុវត្ថិភាព</u>

សញ្ញាស្តង់ដារសុវត្ថិភាពមិនត្រូវបានកំណត់អំពីពណ៌ឡើយ ប៉ុន្តែទំហំអាចតូច ឬធំបានដោយត្រូវសមាមាត្រទៅនឹងគំរូ ដែលមានភ្ជាប់ជាមួយនៅក្នុងឧបសម្ព័ន្ធ " ខ " ។

៣-សញ្ញាចុះបញ្ជីផលិតផលសំរាប់បិទភ្ជាប់ ឬបោះពុម្ពនៅលើស្លាកផលិតផលដែលបានអនុលោមតាមស្តង់ដារឧស្សាហកម្មកម្ពុជា **CS001-2000** " ការបិទស្លាកផលិតផល ចំណីអាហារ "

និងនៅលើផលិតផលដែលស្តង់ដារឧស្សាហកម្មកម្ពុជាពុំទាន់មាន ។

សញ្ញាចុះបញ្ជីផលិតផលមានអក្សរ " ចបផ " ចារិកក្នុងរង្វង់រាងពងក្រពើ និងភ្ជាប់ទៅដោយលេខសំគាល់ " xxyyy/zz " អក្សរនិងលេខនេះចារិកក្នុង ចតុកោណកែង ។

ចបផ XXYYY/ZZ

<u>សញ្ញាចុះបញ្ជីផលិតផល</u>

**ចបផ:** ចុះបញ្ជីផលិតផល ( ប្រើ Font Limon F2 )

**XX** : លេខក្រុមផលិត

**YYY**: លេខរៀងផលិតផល

**ZZ**: ឆ្នាំចុះបញ្ជីផលិតផល

សញ្ញាចុះបញ្ជីផលិតផល មិនត្រូវបានកំណត់អំពីពណ៌ឡើយ ប៉ុន្តែទំហំអាចតូច ឬធំបានដោយត្រូវសមាមាត្រទៅនឹងគំរូដែលមានភ្ជាប់ជាមួយនៅក្នុងឧបសម្ព័ន្ធ " គ " ។

**<u>ប្រការ២:</u>** ក្រុមហ៊ុន រោងចក្រ សហគ្រាស និងសិប្បកម្មដែលផលិត និង/ឬនាំចូលផលិតផលសំរាប់ធ្វើចរាចរក្នុងព្រះរាជាណាចក្រកម្ពុជា អាចប្រើសញ្ញាស្តង់ដារឧស្សាហកម្មកម្ពុជាបិទភ្ជាប់ ឬ បោះពុម្ពលើស្លាកផលិតផលរបស់ខ្លួនបាន បន្ទាប់ពីបានទទួលអាជ្ញាប័ណ្ណស្តង់ដារពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**<u>ប្រការ៣:</u>** ប្រកាស ឬសេចក្តីសំរេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**<u>ប្រការ៤:</u>** ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**ស៊ុយ សែម**

**<u>ចម្លងជូន:</u>**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីគោរពជូនជ្រាប)
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ
- ក្រសួងព័ត៌មាន
- ក្រសួងអប់រំយុវជននិងកីឡា
- រាជបណ្ឌិតសភាកម្ពុជា
- គ្រប់សាលាខេត្ត-ក្រុង
- សភាពាណិជ្ជកម្មកម្ពុជា
- គ្រប់មន្ទីរឧស្សាហកម្មរ៉ែនិងថាមពលខេត្ត-ក្រុង (ដើម្បីសហការអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ "ក"

## សញ្ញាស្តង់ដារផលិតផល



## ឧបសម្ព័ន្ធ "ខ"

## សញ្ញាសុវត្ថិភាព



## ឧបសម្ព័ន្ធ "គ"

## សញ្ញាចុះបញ្ជីផលិតផល




